**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧...០៦៧...២១០...ធ.ជ.ក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការហាមឃាត់ទទួលយកអត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្តល់ឥណទាន

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូន លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ មេត្តាជ្រាបថា កន្លងមក ធនាគារជាតិនៃកម្ពុជាបានពិនិត្យឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួន ជាពិសេស ប្រតិបត្តិករឥណទានជនបទ បាននឹងកំពុងផ្តល់ឥណទានដល់អតិថិជនរបស់ខ្លួនដោយទទួលយកនូវអត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជាវត្ថុធានាក្នុងការផ្តល់ឥណទាន ដែលជាការអនុវត្តមិនត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិធរមាន ។ ធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ថា អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ជាប្រភេទលិខិតយថាភូតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច សម្រាប់បញ្ជាក់អត្តសញ្ញាណបុគ្គល និងសម្រង់ស្ថិតិប្រជាពលរដ្ឋតែប៉ុណ្ណោះ ។ លិខិតយថាភូតមិនមែនជាទ្រព្យសម្រាប់ការដាក់បញ្ចាំ ឬជាទ្រព្យធានាក្នុងប្រតិបត្តិការផ្តល់ឥណទានឡើយ ពីព្រោះថា លិខិតទាំងនោះមិនមានតម្លៃសេដ្ឋកិច្ចសម្រាប់សកម្មភាពពាណិជ្ជកម្ម ។ ដូច្នេះ គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ត្រូវបញ្ឈប់ជាបន្ទាន់ ចំពោះការទទួលយកនូវ អត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជាវត្ថុធានាលើការផ្តល់ឥណទាន ។ ក្នុងករណី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទណាមិនអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន គ្រឹះស្ថាននឹងត្រូវរងការពិន័យតាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ជ្រាបនិងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

**ត.ប.ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**គិម វ៉ាដា**